**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/២៣-០៩-២០២១-អវតក/អជតក(០៦) |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 08-Nov-21, 14:10
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយរបស់ យឹម ទិត្យ តបទៅនឹង បណ្តឹងសាទុក្ខរបស់ខ្លួន អំពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចដែលត្រូវបានតម្រូវដោយក្របខ័ណ្ឌគតិយុត្ត អ.វ.ត.ក**

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. HOLLIS
**សហព្រះរាជអាជ្ញាអន្តរជាតិ**

**ចម្លងជូន:**
លោកស្រី ជា លាង
**សហព្រះរាជអាជ្ញាជាតិ**

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Chandra N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**សហមេធាវី យឹម ទិត្យ:**
លោក សូ មូហ្សេទ្ធី
Suzana TOMANOVIĆ

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុង សំណុំរឿង ០០៤**

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សុំឆ្លើយតបទៅនឹងចម្លើយរបស់ យឹម ទិត្យ[1] តបទៅនឹងបណ្តឹងសាទុក្ខរបស់គាត់ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") ក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចដែលត្រូវបានតម្រូវដោយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក[2]។ សម្រាប់មូលហេតុដូចបានពិភាក្សាខាងក្រោម ស.ព.អ ស្នើសុំឱ្យ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បដិសេធចោលចម្លើយតបនេះ និងអនុញ្ញាតទទួលយកដំណោះស្រាយដែលស្នើសុំនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន។

## II. សហចៅក្រមស៊ើបអង្កេតមិនមានយុត្តាធិការផ្តាច់មុខទេ

2. ផ្ទុយទៅនឹងការអះអាងរបស់ យឹម ទិត្យ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") "មិនមានយុត្តាធិការផ្តាច់មុខ" លើរឿងក្តីនេះ ដោយផ្អែកលើមូលហេតុមួយចំនួន[3]។ ទីមួយ ស.ច.ស *ពុំមានសិទ្ធិអំណាចផ្លូវការបន្ថែម (functus officio)* ភ្លាមៗបន្ទាប់ពីការចេញដីកាដំណោះស្រាយ លើកលែងតែមុខងាររដ្ឋបាល ដែលមានចែងយ៉ាងច្បាស់នៅក្នុងក្របខណ្ឌ អ.វ.ត.ក។ ទីពីរ ស.ច.ស មិនមានយុត្តាធិការដែលមានជាប់មកជាមួយណាមួយ ដែលនឹងដណ្តើមយកសិទ្ធិសំណាចរបស់អង្គជំនុំជម្រះនេះ ដែលកំពុងប្តឹងអំពីសំណុំរឿង ០០៤ នេះទេ។ ក្នុងករណីណាក៏ដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមែនជាវេទិកាត្រឹមត្រូវ ក្នុងការនាំមកនូវភាពប្រាកដប្រជា ព្រោះថាសេចក្តីសម្រេចណាមួយ ដែលចេញនឹងត្រូវប្តឹងឧទ្ធរណ៍បន្តទៀត។ ជាងនេះទៀត តាមក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ស.ច.ស មិនមានសិទ្ធិអំណាចក្នុងការមោឃភាពដីកាដំណោះស្រាយរបស់ខ្លួន

---

[1] សំណុំរឿង ០០៤/២៣-០៩-២០២១-អ.វ.ត.ក/អ.ជ.ត.ក (០៦)-2/1 ចម្លើយរបស់ យឹម ទិត្យ តបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចដែលត្រូវបានតម្រូវដោយក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ ("ចម្លើយតប")។ ដោយសារតែសំណៅជាភាសាអង់គ្លេសនៃចម្លើយតប មានលេខកថាខណ្ឌមិនត្រឹមត្រូវ ស.ព.អ ដាក់ភ្ជាប់សំណៅត្រឹមត្រូវដើម្បីងាយស្រួលក្នុងការយោង (*សូមមើល* ឧបសម្ព័ន្ធ ក - ការដាក់លេខកថាខណ្ឌដែលបានកែតម្រូវ) ហើយដកស្រង់តាមលេខកថាខណ្ឌត្រឹមត្រូវទាំងនោះនៅក្នុងការឆ្លើយតបនេះ (ដែលត្រូវគ្នានឹងសំណៅជាភាសាខ្មែរ)។

[2] សំណុំរឿង ០០៤/២៣-០៩-២០២១-អ.វ.ត.ក/អ.ជ.ត.ក (០៦)-2 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចដែលត្រូវបានតម្រូវដោយក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ចុះថ្ងៃទី ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ("បណ្តឹងសាទុក្ខរបស់ ស.ព.អ")។

[3] *សូមមើល* ចម្លើយតបកថាខណ្ឌ ១, ២០-២៦។

នោះទេ។ ជាចុងក្រោយ ផ្អែកលើអគតិជាក់ស្តែងរបស់ខ្លួន និងការបង្ហាញឲ្យឃើញនូវអគតិ ស.ច.ស ត្រូវបានដកហូតសិទ្ធិក្នុងការពិចារណាថាតើរឿងក្តីគួរបន្តដំណើការទៅជំនុំជម្រះ ឬទេ ពីព្រោះពួកគាត់ បានធ្វើការកំណត់ទុកជាមុនលើបញ្ហានេះ។

## ក. ស.ច.ស មិនត្រូវបានប្តឹងអពី សំណុំរឿង ០០៤ ទេ

3. ចម្លើយតបនេះមើលរំលងអង្គហេតុដែលថា គឺ អ.ប.ជ (ហើយពេលនេះ អ.ជ.ត.ក)[4] ដែល "ជាយុត្តាធិការចុងក្រោយលើការស៊ើបអង្កេត"[5] មិនមែន ស.ច.ស ទេ។ ស.ច.ស "លែងមានសិទ្ធិអំណាចផ្លូវការបន្ថែមទៀតហើយ បន្ទាប់ពីបានចុះហត្ថលេខាលើផ្នែកសេចក្តីសម្រេចនៃដីកាដំណោះស្រាយរួច"[6]។ ដូច្នេះ សិទ្ធិអំណាចរបស់ ស.ច.ស មានតែតាមបែបរដ្ឋបាល "ចាត់ការសំណុំរឿង

[4] *សូមមើល* បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ១៣ (ច្បាប់ជាធរមាន ស្តីពីយុត្តាធិការដែលមានជាប់មកជាមួយរបស់ អ.ជ.ត.ក) ផ្នែក IV (ភាពអាចទទួលយកបាន)។

[5] សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ("សេចក្តីសម្រេចរួមរបស់ អ.ប.ជ") កថាខណ្ឌ ៦៩ (*ដកស្រង់ ក្នុងចំណោមរឿងផ្សេងទៀត* សំណុំរឿង ០០១-**D99/3/42** សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ បញ្ជូនខ្លួន កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច" ទៅជំនុំជម្រះ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៤១។ សំណុំរឿង ០០៤/២-**D359/24 & D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ៤១។ សំណុំរឿង ០០៤/២-**D360/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការកោសលុប និងការចាត់វិធានការបណ្តោះអាសន្ន ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ៥, ១៣។ *សូមមើលផងដែរ* សំណុំរឿង ០០៣-**D266/27 & D267/35** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ("សេចក្តីពិចារណា អ.ប.ជ ក្នុងសំណុំរឿង ០០៣") យោបល់របស់ចៅក្រម Olivier Beauvallet និង Kang Jin Baik ("យោបល់របស់ចៅក្រមអន្តរជាតិ") កថាខណ្ឌ ១៣២-១៣៣ ("មាត្រា ១២(២) នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង "ការិយាល័យតុលាការចុងក្រោយដែលទទួលបានសំណុំរឿងត្រូវធ្វើការពិនិត្យឡើងវិញ ចំពោះឯកសារស្តីពីសុវត្ថភាពនៃការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញនៅក្នុងសំណុំរឿង [...] គឺអង្គបុរេជំនុំជម្រះ ឬ អង្គជំនុំជម្រះតុលាការកំពូល")។

[6] សំណុំរឿង ០០៤/១-**D308/3/1/20** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ ជើងទំព័រ ១៨៦ *ដកស្រង់ ក្នុងចំណោមរឿងផ្សេងទៀត* សំណុំរឿងលេខ ០០៣-**D266/27 & D267/35** សេចក្តពិចារណាក្នុងសំណុំរឿង ០០៣ យោបល់របស់ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៣២។ អំណះអំណាងរបស់ ស.ច.ស ថា ពួកគាត់មិនអាចលែងមានសិទ្ធិអំណាចផ្លូវការបន្ថែមទៀតនោះទេ ពីព្រោះតែនៅក្នុងសំណុំរឿង ០០៤/២ ចៅក្រម អ.ប.ជ បានចេញសេចក្តីណែនាំទៅកាន់អង្គភាពបណ្ណសារ ពីរបៀបដំណើរការរឿងក្តី មើលរំលងថា

ដោយអនុលោមតាមវិធាន ៧៧(១៣) និង ៧៧(១៤) នៃវិធានផ្ទៃក្នុង"[7] តែប៉ុណ្ណោះ ដោយការបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ ដែលខ្លួនបានបដិសេធមិនធ្វើដូច្នេះ[8]។ ពួកគាត់លែងមានសិទ្ធិអំណាចក្នុងការចេញសេចក្តីសម្រេច និងដីកាជាសារធាតុ ដែលទាក់ទងនឹងដំណាក់កាលមុនការជំនុំជម្រះនោះទេ[9]។

---

សេចក្តីណែនាំទាំងនោះបានកើតឡើងនៅក្នុងខែមករា *មុនពេល*ដែលការិយាល័យសហចៅក្រមស៊ើបអង្កេត ត្រូវបានបង្កើតឡើងវិញត្រឹមត្រូវ ដោយការដាក់ឱ្យដំណើរការឡើងវិញនៃ ស.ច.ស.អ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០។ *សូមមើល* សំណុំរឿង ០០៣-**D270/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ("សេចក្តីសម្រេចបដិសេធ របស់ ស.ច.ស") កថាខណ្ឌ ៣៨។ សំណុំរឿង ០០៤/២-**D359/36 & D360/45** អនុស្សរណៈអន្តរការិយាល័យពីចៅក្រម Olivier Beauvallet និង Kang Jin Baik មានចំណងជើងថា "ការបញ្ជូនសំណុំរឿង ០០៤/២" ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ២៧-២៨, ៣១។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក *សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបានតែងតាំងឡើងវិញ* ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០។ *សូមមើលផងដែរ* សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧២។

[7] សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧២។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ដូចដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធានផ្ទៃក្នុង") ឬ ("វិធាន")។ *សូមមើលផងដែរ* សំណុំរឿង០០៣-**D266/27 & D267/35** សេចក្តីពិចារណាក្នុងសំណុំរឿង ០០៣ ទំព័រ ៥៦ (ផ្នែកសម្រេចសេចក្តី)។ ឯកសារ **D381/45 & D382/43** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ("សេចក្តីពិចារណា") ទំព័រ ៦៩-៧០ (ផ្នែកសម្រេចសេចក្តី)។

[8] ស.ច.ស មិនបានអនុវត្តតាមអាណត្តិគតិយុត្តិផ្ទាល់របស់ អ.វ.ត.ក ក្នុងការបញ្ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងរួមគ្នា ឬជាឯកត្តោភាគី ទៅកាន់អង្គជំនុំជម្រះសាលាដំបូងនោះទេ ក្នុងសំណុំរឿង ០០៣ បានបញ្ជាក់ច្បាស់ថា ពួកគេនឹងមិនធ្វើដូច្នោះឡើយ ប្រសិនបើមិនមានសេចក្តីណែនាំច្បាស់លាស់ពី អ.ប.ជ។ *សូមមើល* បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភ្នំពេញ ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ៥(៤), ៧(៤)។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានកែប្រែនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អ.វ.ត.ក") មាត្រា ២៣ ថ្មី។ វិធាន ១(២)។ សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៦៧ ("ជាគោលការណ៍ សហចៅក្រមស៊ើបអង្កេតមួយរូបអាចបំពេញកិច្ចតែម្នាក់ឯងដោយត្រឹមត្រូវ") រួមទាំងជើងទំព័រលេខ ១៨១។

[9] សំណុំរឿង ០០៣-**D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៦៩។ ចំណុចនេះមានន័យថា ស.ច.ស ក៏មិនមានសិទ្ធិអំណាចគតិយុត្តិ ដើម្បីធ្វើមោឃភាព ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព *សូមមើល* បណ្តឹងសាទុក្ខរបស់ ស.ព.អ ផ្នែក V (អង្គសេចក្តី)។

4. បណ្តឹងឧទ្ធរណ៍ជាច្រើនត្រូវបានដាក់ប្រឆាំងនឹងដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤ ហើយ ស.ច.ស បានទទួលស្គាល់ថា ពួកគាត់មិនមានយុត្តាធិការទេ ក្នុងករណីដែល មានមធ្យោបាយគតិយុត្តិផ្សេងទៀត "ដើម្បីជម្រុញដល់សំណុំរឿងនេះ ឱ្យទៅជំនុំជម្រះ ឬទៅដល់ការបិទបញ្ចប់"[10]។ នៅក្នុងសំណុំរឿង ០០៤/២ ស.ច.ស មិនព្រមសម្រេចលើសំណើរបស់ អោ អាន សុំឱ្យបោះត្រា និងរក្សារឿងក្តីទុកក្នុងបណ្ណសារ នៅពេលដែល ស.ព.អ ក្រោយមកបានប្តឹងសាទុក្ខទៅ អ.ជ.ត.ក[11]។ ក្នុងសំណុំរឿង ០០៣ ស.ច.ស បានស្នើសុំ ស.ព.អ ឱ្យបញ្ជាក់ពីបំណងរបស់គាត់ក្នុងការប្តឹងទៅ អ.ជ.ត.ក នូវរឿងក្តីនេះ *និង* បានណែនាំភាគីថា ប្រសិនបើ អ.ជ.ត.ក មិនតម្រូវបានប្តឹងទេនោះ សុំពួកគេផ្តល់នូវសេចក្តីសន្និដ្ឋានជាលាលក្ខណ៍អក្សរស្តីពីយុត្តាធិការរបស់ ស.ច.ស ក្នុងការបញ្ចប់[12]។

## ខ. ស.ច.ស មិនមានយុត្តាធិការដែលមានជាប់មកជាមួយនោះទេ

5. ស.ច.ស ក៏មិនមានយុត្តាធិការដែលមានជាប់មកជាមួយលើរឿងក្តីនេះទេ អនុលោមតាមវិធាន ២១ ឬវិធានផ្សេងទៀត[13]។ ដូចបានបង្ហាញខាងលើ[14] ស.ច.ស មិនត្រូវបានប្តឹងអំពីសំណុំរឿង ០០៤ ទេ

[10] សំណុំរឿង ០០៣-**D270/7** សេចក្តីសម្រេចបដិសេធ របស់ ស.ច.ស កថាខណ្ឌ ៤២ ("ប្រសិនបើមិនមានមធ្យោបាយណាផ្សេង ដើម្បីជម្រុញដល់សំណុំរឿងនេះ ឱ្យទៅជំនុំជម្រះ ឬទៅដល់ការបិទបញ្ចប់ [...] ហើយប្រសិនបើ *មិនមាន* ស្ថាប័នតុលាការដទៃណា នៅក្នុងតុលាការនេះ មានចេតនាក្នុងការទទួលយកមកអនុវត្តដោយខ្លួនឯង *នូវមធ្យោបាយណាមួយនោះជាជម្រើសចុងក្រោយបំផុត* និង *បន្ទាប់ពីដំណើរការអស់នូវយុត្តាធិការ ទាំងឡាយដែលមាន* ពួកយើងនឹងបើកឱកាស [...] ថាតើពួកយើងមានយុត្តាធិការដែលនៅសេសសល់ពិសេសណាមួយ *ដែលជាមធ្យោបាយចុងក្រោយបំផុត* ក្នុងការបិទបញ្ចប់សំណុំរឿងដោយខ្លួនឯង" (គូសបញ្ជាក់បន្ថែម))។ *សូមមើលផងដែរ* កថាខណ្ឌ ៤០។

[11] សំណុំរឿង ០០៤/២-**D364** អនុស្សរណៈពីសហចៅក្រមស៊ើបអង្កេត មានចំណងជើងថា "សំណើរបស់មេធាវីការពារក្តី ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ - ឯកសារ D363 ("សំណើរ") ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ ទំព័រ១។

[12] សំណុំរឿង ០០៣-**D273** ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ("ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានបញ្ចប់សំណុំរឿង") ផ្នែកសម្រេចសេចក្តី។ *សូមមើលផងដែរ* កថាខណ្ឌ ៥, ៧។

[13] *ផ្ទុយពី* ឯកសារ **D386** សំណើរបស់ យឹម ទិត្យ សុំសហចៅក្រមស៊ើបអង្កេតឱ្យ បញ្ចប់ បោះត្រា ដាក់បញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណាសារជាបន្ទាន់ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ("សំណើរបស់ យឹម ទិត្យ សុំឱ្យបញ្ចប់") កថាខណ្ឌ ៩-១២ ដែលគាត់បានយោងដោយប្រយោលទៅចម្លើយតប កថាខណ្ឌ ២៦ នៅពេលដែលគាត់លើកឡើងថា "ស.ច.ស មានយុត្តាធិការផ្តាច់មុខ និងបានទទួលសំណើរបស់មេធាវីការពារក្តី ដាក់ទៅ ស.ច.ស" ។

[14] *សូមមើល* កថាខណ្ឌ ៣-៤ *យោងខាងលើ*។

ហើយមិនអាចដណ្ដើមយកអំណាចរបស់អង្គជំនុំជម្រះផ្សេងទៀតនៃ អ.វ.ត.ក ដែលមានសិទ្ធិលើរឿងក្ដីយ៉ាងត្រឹមត្រូវនោះបានឡើយ។

6. ក្នុងករណីណាក៏ដោយ អង្គជំនុំជម្រះនៃ អ.វ.ត.ក ទាំងអស់ បានបញ្ជាក់យ៉ាងច្បាស់ថា ភាពទទួលយកបានអនុលោមតាមវិធាន២១ គឺមានលក្ខណៈពិសេស និងអាចត្រូវបានប្រើតែនៅពេលដែលអង្គហេតុនិងកាលៈទេសៈជាក់លាក់នានាតម្រូវឱ្យធ្វើដូច្នេះប៉ុណ្ណោះ[15]។ ដោយហេតុថា បញ្ហាជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ណាមួយ ដែល យឹម ទិត្យ អាចចង់លើកឡើង អាចត្រូវបានស្ដាប់ដោយ អ.ជ.ត.ក ដែលបច្ចុប្បន្នត្រូវបានប្ដឹងអំពីសំណុំរឿង ០០៤ មិនមានមូលហេតុពិសេស ដែលចាំបាច់តម្រូវឱ្យមានអន្តរាគមន៍របស់ ស.ច.ស នោះទេ។

## គ. ស.ច.ស ពុំមានសិទ្ធិអំណាចផ្លូវច្បាប់ដើម្បីច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ

7. ស.ច.ស ពុំមានយុត្តាធិការក្នុងការប្រើប្រាស់សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ក្នុងរឿងក្ដីមួយ (សំណុំរឿង ០០៤/២) ដើម្បី*ធ្វើឱ្យ* ដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅជាមោឃៈ និងអសុពលភាព នៅក្នុងរឿងក្ដីមួយផ្សេងទៀតបានឡើយ (សំណុំរឿង ០០៤)[16]។ ដូចករណីសំណុំរឿង ០០៤ ដែលបច្ចុប្បន្ន

---

[15] *សូមមើលឧទាហរណ៍* <u>អ.ជ.ត.ក</u>៖ សំណុំរឿង០០២-**E154/1/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទិននឹងការប្រាស្រ័យទាក់ទងការងារជាមួយតែភាគីម្ខាងរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ១៤-១៥។ <u>អ.ប.ជ</u>៖ សំណុំរឿង០០២-**A410/2/6** សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ទៅនឹងសំណើរស្ដីពីការរក្សាការសម្ងាត់ សមភាព និងភាពយុត្តិធម៌ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ១០។ <u>ក.ស.ច.ស</u>៖ ឯកសារ **D185/1** ដីកាសម្រេចស្ដីពីញត្តិរបស់ តា អាន ស្នើសុំមោឃភាពកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន៧៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ ("សេចក្ដីសម្រេចស្ដីពីមោឃភាពក្នុងរឿងក្ដី អោ អាន") កថាខណ្ឌ ២៩ ("ការអនុវត្តវិធានផ្ទៃក្នុង ២១ ដើម្បីជាមធ្យោបាយទទួលបានញត្តិផ្សេងៗ/សំណើដែលមិនអាចទទួលយកតាមវិធានផ្ទៃក្នុងផ្សេងទៀត គឺត្រូវបានចាត់ទុកថាការអនុវត្តក្នុងករណីពិសេស ហើយអាចប្រើប្រាស់បានតែក្នុងករណីដែលអង្គហេតុ និងកាលៈទេសៈតម្រូវឱ្យប្រើប្រាស់បែបនោះប៉ុណ្ណោះ") ជើងទំព័រ ៣៧ ("ទោះបីជាការប្រើប្រាស់វិធានផ្ទៃក្នុង ២១ ជាមធ្យោបាយនីតិវិធីមួយដើម្បីស្នើសុំសំណើប្រភេទផ្សេងៗត្រូវបានពិភាក្សានៅក្នុងរង្វង់កិច្ចដំណើរការនីតិវិធីបណ្ដឹងឧទ្ធរណ៍ [ស.ច.ស] យល់ឃើញថា ការដាក់កម្រិតដោយអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល អាចអនុវត្តបានយ៉ាងសមស្របលើញត្តិ ដែលបានដាក់នៅតុលាការថ្នាក់ដំបូង")។

[16] *សូមមើល* សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ("សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើបណ្ដឹងសាទុក្ខភ្លាមៗ")។ *ផ្ទុយពី* ឯកសារ **D386** សំណើរបស់ យឹម ទិត្យ សុំឱ្យបញ្ចប់ (ដែលក្នុងនោះគាត់បានបញ្ជាក់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមោឃៈ និងអសុពលភាពហើយ នៅទំព័រ១ និង ត្រង់កថាខណ្ឌ

កំពុងតែនៅជាធរមានដែរ មានន័យថា បន្ទាប់ពីសេចក្ដីពិចារណារបស់ អ.ប.ជ មិនបានបដិសេធ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសំឡេងភាគច្រើនលើសលុប[17] និងមុនពេល អ.ជ.ត.ក ធ្វើការសម្រេចលើបណ្ដឹងសាទុក្ខរបស់ ស.ព.អ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ*នៅតែមានសុពលភាព*។ បន្ថែមលើមូលហេតុច្បាស់លាស់ក្នុងការដាកចេញពីសេចក្ដីសម្រេចរបស់ អ.ជ.ត.ក ក្នុងសំណុំរឿង ០០៤/២ លើបណ្ដឹងសាទុក្ខភ្លាមៗ[18] និងក្រៅអំពីការពិតដែលថា ស.ច.ស *ពុំមានសិទ្ធិ អំណាចផ្លូវការបន្ថែម* ស្របតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ក៏គ្មានបទប្បញ្ញត្តិណាអនុញ្ញាតឲ្យ ស.ច.ស ធ្វើមោឃភាពចំពោះដីកាដំណោះស្រាយរបស់ខ្លួនឯងផងដែរ[19]។

## ឃ. ការកំណត់ជាមុនរបស់ ស.ច.ស អំពីថាតើសំណុំរឿងនេះគួរបន្តទៅជំនុំជម្រះដែលឬអត់ ក៏បានដកហូតសិទ្ធិពួកគាត់ផងដែរ

8. សំណើនោះក៏មើលរំលងថា ស.ច.ស ត្រូវបានដកហូតសិទ្ធិ ដោយសារពួកគេបានកំណត់ជាមុនរួចហើយអំពីលទ្ធផលនៃរឿងក្ដីនេះ ការប្រើតេស្ដសាកល្បងផ្លូវច្បាប់សម្រាប់អគតិ ដែលត្រូវបានប្រើប្រាស់ជាប្រចាំនៅ អ.វ.ត.ក និងដោយពិចារណាលើអំពីសច្ចធារណ៍នៃនិរទោស និងលក្ខខណ្ឌ

---

១៣-១៤ និង ១៦) ដែលគាត់បានយោងដោយប្រយោលទៅចម្លើយតប កថាខណ្ឌ ២៦ នៅពេលដែលគាត់លើកឡើងថា "ស.ច.ស មានយុត្តាធិការផ្ដាច់មុខ និងបានទទួលសំណើរបស់មេធាវីការពារក្ដី ដាក់ទៅ ស.ច.ស"។ សំណុំរឿង ០០៣-ឯកសារ **D270/7** សេចក្ដីសម្រេចបដិសេធ របស់ ស.ច.ស កថាខណ្ឌ ៣២, ៣៦។

[17] *សូមមើល* ឯកសារ **D381/45 & D382/43** សេចក្ដីពិចារណា ទំព័រ ៦៩-៧០ (ផ្នែកសម្រេចសេចក្ដី)។

[18] *សូមមើល* ផ្នែក III *ខាងក្រោម*។ ដូចបានពន្យល់បន្ថែមខាងក្រោម សេចក្ដីសម្រេចរបស់ អ.ជ.ត.ក ចេញពីរឿងក្ដីមួយរបស់ អ.វ.ត.ក មិនអាចបន្តសាបព្រោះទៅលើសេចក្ដីសម្រេចផ្សេងទៀតទេ ជាពិសេសករណីដែលមានសំអាងហេតុសមផលដូចជាករណីនេះជាដើម ដែលត្រូវដាកចេញពីសេចក្ដីសម្រេចក្នុងសំណុំរឿង ០០៤/២ របស់ អ.ជ.ត.ក ដែលបានសម្រេចថា ដីកាដំណោះស្រាយពីរបានចេញដោយខុសច្បាប់ គឺត្រូវបានចាត់ទុកជាមោឃៈ និងអសុពលភាព។

[19] អំណាចក្នុងការធ្វើមោឃភាពដីកាដំណោះស្រាយនៅដំណាក់កាលមុនការជំនុំជម្រះ គឺស្ថិតនៅលើ អ.ប.ជ ក្រោយបណ្ដឹងសាទុក្ខក្រោមវិធាន ៦៧(៥), ៧៣, ៧៤ និង ៧៧។ (ដីកាដំណោះស្រាយមិនអាចកែប្រែនីតិវិធីនៃវិធាន ៧៦ បានឡើយ)។ *សូមមើល* វិធាន ៧៦(២) និង (៤)។ សំណុំរឿង ០០៣-ឯកសារ **D158/1** សេចក្ដីសម្រេចលើសំណើរបស់ មាស មុត សុំអង្គបុរេជំនុំជម្រះបកស្រាយទូលាយអំពីវិសាលភាពដែលអាច អនុញ្ញាតបាននៃបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាដំណោះស្រាយ និង បញ្ជាក់បំភ្លឺអំពីនីតិវិធីមោឃភាពដីកាដំណោះស្រាយ ឬ ផ្នែកនានានៃដីកាដំណោះស្រាយ ប្រសិនបើចាំបាច់ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ១៧-១៨)។

ភ័ស្តុតាងកម្រិតខ្ពស់[20] ស.ច.ស ត្រូវបានដកហូតសិទ្ធិក្នុងការពិចារណាលើបញ្ហា ថាតើរឿងក្តីនេះគួរបន្តដំណើរការទៅជំនុំជម្រះ ឬយ៉ាងណា ផ្អែកលើអគតិជាក់ស្តែងរបស់ពួកគេ និងការលេចឡើងនៃអគតិ។ ក្នុងសំណុំរឿង ០០៣ ស.ច.ស បានប្រកាស់ជាចំហរនៅក្នុងសេចក្តីសម្រេចពីររបស់ខ្លួនថា ការបញ្ចប់រឿងក្តី គឺជាជម្រើសតែមួយគត់ដែលពួកគាត់នឹងពិចារណា[21]។ ពួកគាត់ក៏បានផ្តល់ជាយោបល់នៅក្នុងដីកាបង្គាប់តាមផ្លូវតុលាការថា សំណើសុំណាមួយដែល ស.ព.អ អាចធ្វើទៅកាន់ អ.ជ.ត.ក គួរតែជាសំណើសុំឱ្យមានការបញ្ចប់[22]។

9. ទោះបីជា ការកំណត់ជាមុនរបស់ ស.ច.ស ត្រូវបានធ្វើឡើងក្នុងសំណុំរឿង ០០៣ ក៏ដោយ ក៏រឿងក្តីទាំងពីរទាក់ទងនឹងការបរាជ័យក្នុងការបញ្ជូនរឿងក្តីទៅជំនុំជម្រះ ដូចដែលបានកំណត់ដោយក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក រួមទាំងផ្អែកលើមូលដ្ឋាននៃគោលជំហរស្វ័យប្រវត្តិ[23] ហើយ ស.ច.ស

---

[20] រឿងក្តី *Furundžija,* IT-95-17/1-A, សាលដីកា អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០០ កថាខណ្ឌ ១៨៩ (“មានវិធានទូទៅដែលចៅក្រមមិនត្រឹមតែមិនលម្អៀងជាអត្តនោម័តិប៉ុណ្ណោះទេ ប៉ុន្តែចៅក្រមក៏មិនត្រូវស្ថិតក្រោមកាលៈទេសៈអ្វីៗទាំងអស់ដែលនាំឱ្យកើតមាន ឬលេចឡើងនូវអគតិជាសត្យានុម័ត”)។ [...] គោលការណ៍ខាងក្រោមនេះ គួរតែជាសេចក្តីណែនាំក្នុងការបកស្រាយ និងអនុវត្តដោយមិនលម្អៀងនូវលក្ខខណ្ឌតម្រូវនៃច្បាប់លក្ខន្តិកៈ ក) ចៅក្រមមិនលម្អៀង ប្រសិនបើត្រូវបានបង្ហាញថា អគតិជាក់ស្តែងបានកើតឡើង។ ខ) មានការលេចឡើងនៃអគតិដែលមិនអាចទទួលយកបាន ប្រសិនបើ [...] កាលៈទេសៈនានានឹងនាំឱ្យអ្នកសង្កេតការណ៍សមហេតុផលនិងដែលបានជ្រួតជ្រាបម្នាក់ នឹងយល់បានដោយសមហេតុផលអពីអគតិ”)។ ១៩០ (“អ្នកសង្កេតការណ៍សមហេតុផល” គឺជាបុគ្គលដែលបានជ្រួតជ្រាប មានចំណេះដឹងអំពីកាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងប្រពៃណីនៃសុចរិតភាព និងអនាគតិដែលបង្កើតបានជាផ្នែកមួយនៃសារតា ហើយបានផ្តល់ដំណឹងផងដែរអំពីការពិតដែលថា អនាគតិគឺជាករណីកិច្ចមួយរបស់ចៅក្រមដែលបានស្បថលើកតម្កល់យ៉ាងខ្ពស់”)។ សំណុំរឿង ០០២-ឯកសារ **C11/29** សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់... 

[21] *សូមមើល* សំណុំរឿង ០០៣-ឯកសារ **D270/7** សេចក្តីសម្រេចបដិសេធ របស់ ស.ច.ស កថាខណ្ឌ ១៩, ៣៦-៣៧, ៤២។ សំណុំរឿង ០០៣-ឯកសារ **D273** ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីការបញ្ចប់ កថាខណ្ឌ ៥-៦។ *សូមមើលផងដែរ* សំណុំរឿង ០០៣-ឯកសារ **D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧៤(២) (កត់សម្គាល់ថា “ស.ច.ស ‘បានសម្រេចរួចហើយលើវាសនានៃសំណុំរឿងនេះ’ ក្នុងករណីដែលវាបានវិលត្រឡប់មករកខ្លួន”)។

[22] សំណុំរឿង ០០៣-ឯកសារ **D273** ដីកាបង្គាប់ឱ្យដាក់សេចក្តីសន្និដ្ឋានស្តីពីការបញ្ចប់ កថាខណ្ឌ ៧។

[23] *សូមមើល* ផ្នែកសម្រេចសេចក្តី នៅក្នុងសំណុំរឿង ០០៣-ឯកសារ **D266/27 & D267/35** សេចក្តីពិចារណា អ.ប.ជ ក្នុងសំណុំរឿង ០០៣ ទំព័រ ៥៦ មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហ្វួត វុទ្ធី, ទំព័រ ៥៨-

បានបញ្ជាក់យ៉ាងច្បាស់លាស់ថា គោលជំហររបស់ពួកគាត់បានអនុវត្តដូចគ្នាទៅលើរឿងក្តីទាំងអស់ដែលនៅសេសសល់ រួមទាំងសំណុំរឿង ០០៤ ផង[24]។ តាមពិត សំណើបច្ចុប្បន្នរបស់ យឹម ទិត្យ នៅចំពោះមុខ ស.ច.ស កត់សម្គាល់ថា "ការយល់ព្រមក្នុងការបញ្ចប់រឿងក្តី" របស់ ស.ច.ស ក្នុងរឿងក្តី ០០៣ ធ្វើឱ្យវាជា "អាជ្ញាបញ្ញាសម្រាប់ ស.ច.ស" ក្នុងការធ្វើដូចគ្នាក្នុងសំណុំរឿង ០០៤[25]។ ការកំណត់ជាមុនបែបនេះធ្វើឱ្យពួកគាត់លែងមានសិទ្ធិក្នុងការពិចារណាលើរឿងក្តីនេះ ការអនុញ្ញាតឱ្យពួកគាត់ធ្វើដូច្នោះ នឹងរំលោភបំពានជាក់ស្តែងដល់សិទ្ធិរបស់ភាគី *ទាំងអស់* ក្នុងការទទួលបានការកំណត់ត្រឹមត្រូវយុត្តិធម៌លើបញ្ហានានាដែលបានលើកឡើង និងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការវាយតម្លៃតលម្អៀងលើបញ្ហានានា ដែលតម្រូវសម្រាប់គ្រប់កិច្ចដំណើរការនីតិវិធីតុលាការដ៏គួរឱ្យជឿជាក់ទាំងអស់។

---

៥៩។ មតិយោបល់របស់ចៅក្រមអន្តរជាតិ ទំព័រ ២០៧។ ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា ទំព័រ ៦៩-៧០ មតិយោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី, ទំព័រ ៧៨ យោបល់របស់ចៅក្រម Judges Kang Jin Baik និង Olivier Beauvallet ទំព័រ ៣៥០។ *សូមមើលផងដែរ* សំណុំរឿង ០០៣-ឯកសារ **D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧២, ៧៦។

[24] *សូមមើល* ឯកសារ **D270/7** សេចក្តីសម្រេចបដិសេធ របស់ ស.ច.ស កថាខណ្ឌ ១៩ ("ប្រសិនបើពួកយើងបានទទួលការជូនដំណឹងបែបនេះអំពីមតិរួមគ្នារបស់អង្គបុរេជំនុំជម្រះ [ស្តីពីភាពស្របច្បាប់នៃដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា] ក្នុងលក្ខណៈលឿនជាងនេះនោះ សំណុំរឿងដែលនៅសល់ទាំងអស់អាចនឹងត្រូវបានដោះស្រាយ ឱ្យបានឆាប់បំផុតដូចដែលអាចធ្វើទៅបាន តាមរយៈសេចក្តីសម្រេចរួម ដែលអាចត្រឹមតែជា*ការបញ្ចប់ភ្លាមៗនូវសំណុំរឿងទាំងអស់ដែលនៅសេសសល់* បន្ទាប់ពីការលើកលែងចោទប្រកាន់នៅក្នុងសំណុំរឿង ០០៤/១"។ (គូសបញ្ជាក់បន្ថែម))។ មិនមានអ្នកសង្កេតការណ៍សមហេតុផលណាអាចជឿថា ស.ច.ស នឹងអនុម័តគោលជំហរផ្សេងបន្ទាប់ពីនេះទេ។ *សូមមើល ឧទាហរណ៍* រឿងក្តី *Rudnichenko ទល់នឹង ប្រទេស អ៊ុយក្រែន* លេខ 2775/07, សាលក្រម ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ ១១៦ (ចៅក្រមមួយរូប "បានពិនិត្យពីដំបូងលើអង្គសេចក្តីនៃរឿងក្តីរបស់សហចុងចោទរបស់ម្ចាស់ពាក្យសុំ ខ នៅក្នុងក្របខ័ណ្ឌដែលគាត់បានបញ្ចេញទស្សនៈអំពីការចូលរួមពាក់ព័ន្ធ និងតួនាទីរបស់ពួកគេទាំងពីរនាក់ គឺខ និងចុងចោទ [...]។ រឿងក្តីទាំងពីរដូចបានពោលខាងលើ គឺមានការពាក់ព័ន្ធក្នុងព្រឹត្តិការណ៍ដូចគ្នា និងមានបង្កប់ន័យលើការវាយតម្លៃលើភ័ស្តុតាងដូចគ្នា") ១១៨។ រឿងក្តី *Buscemi ទល់នឹងប្រទេស អ៊ីតាលី* លេខ 29569/95, សាលក្រម ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦៨ (ចៅក្រមមួយរូប "បានប្រើប្រាស់ជាសាធារណៈនូវពាក្យពេចន៍នានាដែលមានបង្កប់ន័យថា គាត់បានបង្កើតទស្សនៈមិនអនុគ្រោះមួយចំពោះករណីរបស់ម្ចាស់ពាក្យសុំ នៅមុនពេលគាត់ឡើងធ្វើជាអធិបតីក្នុងសវនាការដែលត្រូវធ្វើការសម្រេចលើរឿងនោះ បង្ហាញឱ្យឃើញយ៉ាងច្បាស់ក្រឡែតនូវវិសមិតភាពជាមួយនឹងអនាគតិដែលតុលាការណាមួយត្រូវបានតម្រូវ") ៦៩។ រឿងក្តី *Olujić ទល់នឹងប្រទេស ក្រូអាត* លេខ 22330/05, សាលក្រម ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ៥៩, ៦៥, ៦៨។ រឿងក្តី *Lavents ទល់នឹង Latvia*, លេខ 58442/00, សាលក្រម ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ១១៩ (បុរេទស្សនៈដែលបានបង្កើតជាមុនថា ការរួចទោសពេញលេញមិនអាចធ្វើទៅរួចនោះ គឺជាគោលជំហរពិតប្រាកដមួយលើរឿងក្តីដែលមិនទាន់បានធ្វើការសម្រេច និងជាការពេញចិត្តច្បាស់លាស់មួយក្នុងការស្វែងរកពិរុទ្ធភាព) ១២១។

[25] ឯកសារ **D386** សំណើរបស់ យឹម ទិត្យ សុំឱ្យបញ្ចប់ កថាខណ្ឌ ២៩, ៤០។

## III. មានហេតុផលច្បាស់លាស់ក្នុងខាកចេញពីសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខផ្សេងៗ ក្នុងសំណុំរឿង ០០៤/២

10. នៅ អ.ជ.ត.ក ដូចគ្នានឹងតុលាការ និងសាលាក្ដីអន្តរជាតិផ្សេងទៀត[26] *មិនមាន*កាតព្វកិច្ចដាច់ខាត ក្នុងការរក្សាទុកសំអាងហេតុ និងសេចក្ដីសន្និដ្ឋាន នៃរឿងក្ដីកន្លងមកឡើយ។ ទោះបីជាជាទូទៅវាមានលក្ខណៈស្របច្បាប់ សម្រាប់តុលាការមួយអនុវត្តតាមសេចក្ដីសម្រេចពីមុនរបស់ខ្លួន ក្នុងការស្វែងរកភាពប្រាកដប្រជាផ្លូវច្បាប់ ការណ៍នេះគ្រាន់តែជាសច្ចធារណ៍ដែលថា សេចក្ដីសម្រេចទាំងអស់នោះ មានភាពត្រឹមត្រូវប៉ុណ្ណោះ[27]។ ស្រដៀងគ្នានេះដែរ តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស

---

[26] *សូមមើលជាឧទាហរណ៍* លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៤៦ 33 UNTS 993 មាត្រា ៣៨(១)(ឃ), ៥៩។ លក្ខន្តិកទីក្រុងរ៉ូម តុលាការព្រហ្មទណ្ឌអន្តរជាតិ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ("លក្ខន្តិកទីក្រុងរ៉ូម") 2187 UNTS 90 មាត្រា ២១(២)។ សូមមើលបន្ថែម *South West Africa* ដំណាក់កាលទីពីរ សាលក្រម ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៦៦ របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៦៦ មតិដាច់ដោយឡែករបស់ចៅក្រម Van Wyk ទំព័រ ៦៧។ *Barcelona Traction, Light and Power Company, Limited*, អញ្ញត្រកម្ម, សាលក្រម ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៦៤ របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៦៤ មតិដាច់ដោយឡែក ចៅក្រម Tanaka ទំព័រ ៦៥។ ពាក់ព័ន្ធតុលាការ ICTY តុលាការ ICTR និងតុលាកាអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស *សូមមើល យោងខាងក្រោម* ជើងទំព័រ ២៩ ។

[27] *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស អធិប្បាយទូទៅ លេខ ៣២ មាត្រា ១៤ នៃ សិទ្ធិទទួលបានសមភាពនៅចំពោះមុខតុលាការ និងសាលាក្ដី និងការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ CCPR/C/GC/32, ២៣ សីហា ២០០៧ (អធិបាយទូទៅលេខ ៣២) កថាខណ្ឌ ២៦ ("មាត្រា ១៤ [នៃ កតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR")] ធានាតែអំពីសមភាព និងយុត្តិធម៌លើនីតិវិធី ហើយមិនអាចបកស្រាយថាធានា ពីការមិនមានកំហុសឆ្គង លើផ្នែកនៃអង្គជំនុំជម្រះមានសមត្ថកិច្ចឡើយ")។ ស.ច.ស បានកត់សម្គាល់ថា អ.វ.ត.ក ដំណើរការក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលគោលការណ៍នៃទ្រឹស្ដីប្រកាន់យកតាមសេចក្ដីសម្រេចពីមុន មិនអាចអនុវត្តបានឡើយ។ *សូមមើលឧទាហរណ៍* សំណុំរឿង ០០៤/១-**D308/3** ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ("ដីកាដំណោះស្រាយក្នុងរឿងក្ដី អ៊ឹម ចែម (សំអាងហេតុ)") កថាខណ្ឌ ១០។ សំណុំរឿង ០០៣-**D87/2/1.7/1** ដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនិងជម្លោះប្រដាប់អាវុធ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ១៣)។ តាមពិតទៅ សហចៅក្រមស៊ើបអង្កេត បានបដិសេធកន្លងមក មិនគោរពតាមសេចក្ដីសម្រេច របស់អង្គបុរេជំនុំជម្រះ ជាអង្គជំនុំជម្រះទទួលបណ្ដឹងឧទ្ធរណ៍ នៅដំណាក់កាលបុរេជំនុំជម្រះ (*សូមមើលជាឧទាហរណ៍* សំណុំរឿង ០០៤/២ ឯកសារ **D360** ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៣៥-៣៨)។ ជាងនេះទៀត អ.ប.ជ បានលើកឡើងយ៉ាងត្រឹមត្រូវថា "គោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ មិនអាចត្រូវបានបកស្រាយដើម្បីកំណត់ថា ការភ័ន្តច្រឡំនៅក្នុងរឿងក្ដីមួយ នឹងត្រូវអនុវត្តតាម នៅក្នុងរឿងក្ដីមួយទៀត នាពេលអនាគតទេ ទោះបីជាការភ័ន្តច្រឡំនោះ ផ្ដល់ជាប្រយោជន៍ ចំពោះជនត្រូវចោទក៏ដោយ"។ (*សូមមើល* សំណុំរឿង ០០២-ឯកសារ **D390/1/2/4** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយក ការដាក់

បានបញ្ជាក់យ៉ាងច្បាស់ថា "លក្ខខណ្ឌតម្រូវនៃសច្ចភាពគតិយុត្តិ និងការការពារទំនុកចិត្តស្របច្បាប់ចំពោះសាធារណជន មិនអាចសម្របសម្រួលជាមួយសិទ្ធិដែលបានតម្រូវ សម្រាប់ភាពស៊ីចង្វាក់គ្នានៃយុត្តិសាស្ត្រឡើយ"[28]។ ស.ព.អ យល់ស្របជាមួយ យឹម ទិត្យ ថា សូម្បីតែក្នុងករណីដែលរឿងក្តីពីរស្រដៀងគ្នា ប្រសិនបើមាន "សំអាងហេតុត្រឹមត្រូវសមហេតុផល" ក្នុងការងាកចេញពីសេចក្តីសម្រេចកន្លងមក តុលាការត្រូវតែអនុវត្តដូច្នេះ ដើម្បីជាប្រយោជន៍យុត្តិធម៌[29]។

---

ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៥)។

[28] រឿងក្តី *Stanković និង Trajković តទល់នឹង ប្រទេសស៊ែប៊ី* សំណុំរឿងលេខ ៣៧១៩៤/០៨ និង ៣៧២៦០/០៨ សាលក្រម ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៤០(៦) (បញ្ជាក់ថា "ការវិវឌ្ឍន៍ករណីយុត្តិសាស្ត្រផ្ទាល់មិនផ្ទុយទៅនឹងរដ្ឋបាលតុលាការត្រឹមត្រូវនោះទេ ដោយហេតុថា ការបរាជ័យក្នុងរក្សាវិធីសាស្ត្រដ៏ស្វាហាប់ និងប្រែប្រួល នឹងមានហានិភ័យដល់ការរាំងកំណែទម្រង់ ឬការធ្វើឱ្យប្រសើឡើង"។ សូមមើលផងដែរ រឿងក្តី *Unédic តទល់នឹង ប្រទេសបារាំង* សំណុំរឿងលេខ ២០១៥៣/០៤ សាលក្រម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ កថាខណ្ឌ ៧៤ (ការបកប្រែក្រៅផ្លូវការ៖ ប៉ុន្តែតុលាការពិចារណាថា លក្ខខណ្ឌតម្រូវនៃសច្ចភាពគតិយុត្តិ និងការការពារការរំពឹងទុកដោយស្របច្បាប់របស់ម្ចាស់បណ្តឹង មិនបានបង្កើតជាសិទ្ធិដែលទទួលបាន ក្នុងយុត្តិសាស្ត្រដែលមានសង្គតភាពឡើយ។")។ រឿងក្តី *Atanasovski តទល់នឹងអតីតសាធារណរដ្ឋយូហ្គោស្លាវីម៉ាសេដូនី* សំណុំរឿងលេខ ៣៦៨១៥/០៣ សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ កថាខណ្ឌ ៣៨។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ការយោងរបស់ យឹម ទិត្យ ទៅរករឿងក្តី *Ştefănică និងអ្នកដទៃទៀត តទល់នឹងប្រទេសរ៉ូម៉ានី* សំណុំរឿងលេខ ៣៨១៥៥/០២ សាលក្រម ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ ("រឿងក្តី *Ştefănică*") កថាខណ្ឌ ៣៧-៣៨ ក្នុងឯកសារ **D386** សំណើរបស់ យឹម ទិត្យ សុំឱ្យបញ្ចប់ ជើងទំព័រ ៣៨ មិនបានផ្លាស់ប្តូការសន្និដ្ឋាននេះឡើយ។ ផ្ទុយគ្នានឹងការអះអាងរបស់ យឹម ទិត្យ ក្នុង ឯកសារ **D386** សំណើរបស់ យឹម ទិត្យ សុំឱ្យបញ្ចប់ កថាខណ្ឌ ១៧ និង ៤២) រឿងក្តី *Ştefănică* មិនមែនជាឯកសារ សម្រាប់ការអះអាងថា តុលាការចាំបាច់ត្រូវគោរពតាម សេចក្តីសម្រេចដែលខុសឆ្គងកន្លងមកទេ។ ប៉ុន្តែតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បានសម្រេចថា មានការរំលោភទៅលើមាត្រា ៦ ដោយផ្អែកលើការអនុវត្តច្បាប់តាមអំពើចិត្ត ដែលនាំទៅដល់ "ការជំនុំជម្រះដែលមិនស៊ីចង្វាក់គ្នា ចំពោះបណ្តឹងដែលលើកឡើង ដោយមនុស្សជាច្រើននាក់នៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា ដែលនាំទៅដល់ស្ថានភាពមិនប្រាកដប្រជា"។ *Ştefănică* កថាខណ្ឌ ៣៨ តុលាកាអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ការពារប្រជាជនពីងាកចេញតាមអំពើចិត្ត និងដូចៗគ្នា ក្នុងការអនុវត្តច្បាប់ គឺមិនមែនការវិវឌ្ឍច្បាប់ដែលបានពិចារណា ដែលរួមមានការកែតម្រូវ ទៅលើយុត្តិសាស្ត្រដែលខុសឆ្គងឡើយ។

[29] ចម្លើយតប កថាខណ្ឌ ១៨ ("នៅពេលដែលបណ្តឹងសាទុក្ខភ្លាមៗ ស្នើសុំ អ.ជ.ត.ក ឱ្យងាកចេញពីសេចក្តីសម្រេចមុនផលប្រយោជន៍នៃសច្ចភាពផ្លូវច្បាប់ និងភាពអាចព្យាការណ៍បានតម្រូវឱ្យម្ចាស់បណ្តឹងសាទុក្ខបង្ហាញ "សំអាងហេតុត្រឹមត្រូវសមហេតុផលជាប្រយោជន៍យុត្តិធម៌"។")។ *សូមមើលជាឧទាហរណ៍* រឿងក្តី *Aleksovski* សំណុំរឿងលេខ IT-95-14/1-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ១០៧-១០៨ ("ដើម្បីប្រយោជន៍នៃសច្ចភាព និងភាពអាចប៉ាន់ប្រមាណបាន អង្គជំនុំជម្រះតុលាការកំពូល គួរតែគោរពតាមសេចក្តីសម្រេចកន្លងមករបស់ខ្លួន ប៉ុន្តែអង្គជំនុំជម្រះមានសេរីភាពក្នុងការងាកចេញ ពីសេចក្តីសម្រេចកន្លងមក បើមានសំអាងហេតុសមស្រប ដើម្បីជាប្រយោជន៍យុត្តិធម៌។

ដូចបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន[30] ផ្ទុយទៅនឹងការអះអាងរបស់ យឹម ទិត្យ[31] ស.ព.អ បានបង្ហាញមូលហេតុច្បាស់លាស់សម្រាប់ អ.ជ.ត.ក ងាកចេញពីសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗក្នុងសំណុំរឿង ០០៤/២ របស់ខ្លួន ជាពិសេស "កំហុសឆ្គងច្បាស់មួយនៅសំអាងហេតុរបស់ អ.ជ.ត.ក ឬ ការផ្លាស់ប្តូរមួយនៅក្នុងកាលៈទេសៈ" ដែលចាំបាច់ត្រូវមានការងាកចេញបែបដូច្នេះ[32]។

---

ឧទាហរណ៍នៃស្ថានភាពដែល សំអាងហេតុសមស្របដើម្បីប្រយោជន៍យុត្តិធម៌ តម្រូវឱ្យមានការងាកចេញ ពីសេចក្តីសម្រេចកន្លងមក មានដូចជាករណីដែលសេចក្តីសម្រេចកន្លងមក ត្រូវបានសម្រេចដោយផ្អែកលើមូលដ្ឋាន នៃគោលការណ៍គតិយុត្តិ ឬរឿងក្តីមិនត្រឹមត្រូវ ដែលសេចក្តីសម្រេចកន្លងមក ត្រូវបានធ្វើឡើង ផ្អែកលើសេចក្តីសម្រេចដែលមានស្រាប់")។ រឿងក្តី *Semanza* សំណុំរឿងលេខ ICTR-97-23-A ដីកាសម្រេច អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ កថាខណ្ឌ ៩២។ រឿងក្តី *Galić* សំណុំរឿងលេខ IT-98-29-Aសាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ១១៧។ រឿងក្តី *Kordić & Čerkez* សំណុំរឿងលេខ IT-95-14/2-Aសាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១០៤០។ រឿងក្តី *Šainović និងអ្នកដទៃទៀត* សំណុំរឿងលេខ IT-05-87-Aសាលដីកា អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ១៦៥០ ("ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូល [...] បានបដិសេធយ៉ាងច្បាស់លាស់ នូវវិធីសាស្ត្រដែលបានអនុម័ត ក្នុងសាលដីការឿងក្តី *Perišić* ដោយសារតែវាប្រឆាំងដោយផ្ទាល់និងជាក់ស្តែង ជាមួយយុត្តិសាស្ត្រដែលនៅជាធរមាន ស្តីពីធាតុផ្សំសត្យានុម័តនៃការទទួលខុសត្រូវលើការជួយ និងជម្រុញ និងជាមួយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងករណីនេះ"។ រឿងក្តី *Cossey តទល់នឹងព្រះរាជាណាចក្រអង់គ្លេស* សំណុំរឿងលេខ ១០៨៤៣/៨៤ សាលក្រម ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩០ កថាខណ្ឌ ៣៥ (តុលាការបានកត់សម្គាល់ថា ទោះបីជាមិនជាប់កាតព្វកិច្ចខ្លាំងក្លាក្តី តែជាធម្មតាតុលាការត្រូវគោរពតាម សេចក្តីសម្រេចកន្លងមករបស់ខ្លួន ហើយអាចងាកចេញពីសេចក្តីសម្រេចទាំងនោះតែក្នុងករណី "មានសំអាងហេតុសមស្រប" ក្នុងការងាកចេញទេ)។ ចំពោះការអនុវត្តកន្លងមក របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សូមមើលសំណុំរឿង ០០៤/១ ឯកសារ **D308/3** ដីកាដំណោះស្រាយក្នុងរឿងក្តី អ៊ឹម ចែម (សំអាងហេតុ) កថាខណ្ឌ ១០ (សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ថា ដើម្បីរក្សា "ភាពច្បាស់លាស់ និងភាពដូចគ្នានៃច្បាប់" ពួកគេនឹងគោរពតាមយុត្តិសាស្ត្ររបស់ អង្គជំនុំជម្រះតុលាការកំពូល ប៉ុន្តែនឹងងាកចេញពីយុត្តិសាស្ត្រនោះ ក្នុងករណីមាន "សំអាងហេតុពិសេស")។ សំណុំរឿង ០០៣ ឯកសារ **D181** ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ស្តីពីយុត្តាធិការបុគ្គល ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ២៨ ("ដើម្បីជាប្រយោជន៍សច្ចភាពផ្លូវច្បាប់ និងសមភាពនៅចំពោះមុខច្បាប់ សហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តគោលការណ៍ច្បាប់ និងវិធានឱ្យស្របតាមការយល់ឃើញរបស់ អ.ជ.ត.ក ប្រសិនបើមិនមានមូលហេតុផ្ទុយសមស្រប")។

[30] បណ្តឹងសាទុក្ខរបស់ ស.ព.អ ផ្នែក V (អង្គសេចក្តី)។

[31] ចម្លើយតប កថាខណ្ឌ ១៨, ២៧, ៣១-៣២, ៣៦-៣៨, ៤០, ៤២។

[32] ចម្លើយតប កថាខណ្ឌ ១៨។

11. ស.ព.អ សូមសន្និដ្ឋានថា សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗក្នុងសំណុំរឿង ០០៤/២ កើតចេញផ្ទាល់មកពីសេចក្តីសន្និដ្ឋានខុសរបស់ អ.ប.ជ ដែលថា ការចេញដីកាដំណោះស្រាយពីរក្នុងពេលតែមួយ គឺជារឿងខុសច្បាប់[33] ដែលបណ្តាលឱ្យ អ.ជ.ត.ក សន្និដ្ឋានដោយខុសឆ្គងថា ជាវិបាក ការចេញបែបនេះធ្វើឱ្យដីកាដំណោះស្រាយនីមួយៗ មោឃៈនិងអសុពលភាព[34]។ ដូចបានរៀបរាប់លម្អិតនៅក្នុងបណ្តឹងសាទុក្ខរបស់ ស.ព.អ មានសំអាងហេតុសមស្រប ច្បាស់លាស់ជាច្រើន សម្រាប់ អ.ជ.ត.ក ក្នុងការងាកចេញពីការសម្រេចពីមុនរបស់ខ្លួន៖ (១) ផ្ទុយពីគោលជំហររបស់ អ.ប.ជ ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា មិនមែនជារឿងខុសច្បាប់ទេ[35] (២) បើទោះបីជាខុសច្បាប់ក្តី ការចេញបែបនេះមិនបានធ្វើឱ្យដីកាដំណោះស្រាយទៅជាមោឃៈ និងអសុពលភាពឡើយ ហើយវាក៏មិនធានាឱ្យមានការបញ្ចប់រឿងក្តីនេះដែរ[36] និង (៣) ដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ ឡើយ ដូច្នេះសំណុំរឿង ០០៤ គួរត្រូវបានបញ្ជូនទៅជំនុំជម្រះ[37]។

### IV. ដំណោះស្រាយសមស្រប គឺការបង្គាប់ឱ្យបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ

12. ដំណោះស្រាយសមស្របចំពោះភាពទាល់ច្រកបច្ចុប្បន្ន គឺការបង្គាប់ឱ្យបញ្ជូនសំណុំរឿងនេះ ទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីធ្វើការជំនុំជម្រះលើ យឹម ទិត្យ មិនមែនបញ្ចប់សំណុំរឿងនេះទេ។ យឹម ទិត្យមិនបានទទួលរងនូវផលប៉ះពាល់សំខាន់ ឬព្យសនកម្មជាក់ស្តែង ដែលនាំឱ្យគាត់មានយុត្តិកម្មក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ឡើយ[38]។ ការទាមទារដែលគ្មានសំអាងហេតុរបស់គាត់ដែលថា "កង្វះការសម្រេចជាស្ថាពរលើកិច្ចស៊ើបសួរដែលមានរយៈពេល១៥ឆ្នាំ" នៅលើរឿងក្តីរបស់គាត់ លើបញ្ហាថាតើ គាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬទេ

---

[33] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ១៨-២០, ៣៦-៤៤។

[34] សំណុំរឿង ០០៤/២-ឯកសារ **E004/2/1/1/2** សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៥១ (រំឭកពីការសម្រេចសេចក្តីជាឯកច្ឆន្ទរបស់ អ.ប.ជ), ៥៣, ៦១, ៦៧-៦៩, ៧១។

[35] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ១៨-២០, ៣៦-៤៤។

[36] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ២១-២៤, ៤៥-៥១។

[37] បណ្តឹងសាទុក្ខ របស់ ស.ព.អ កថាខណ្ឌ ២៥-៣០, ៥២-៥៧។

[38] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៤៦-៥១។

"បង្កើតឱ្យមាន "វិបាកធ្ងន់ធ្ងរ" ចំពោះសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់គាត់ ធ្វើឱ្យការបញ្ចប់រឿងក្ដីនេះជាឧបាស្រ័យដ៏សមស្រប"[39]នោះ ត្រូវតែបរាជ័យ។

13. ពុំមានការពន្យារពេលមិនសមហេតុផលនៅក្នុងរឿងក្ដីនេះទេ។ ចំណុចចាប់ផ្ដើមសម្រាប់ការកំណត់ថាតើកិច្ចដំណើរការនីតិវិធីបានធ្វើឡើងនៅក្នុងពេលវេលាសមស្របដែរឬអត់ គឺចាប់ពីពេលដែលគាត់ត្រូវបានជូនដំណឹងជាផ្លូវការថា គាត់ត្រូវបានចោទប្រកាន់ មានន័យថា ចាប់ពីពេលដែលអាជ្ញាធរមានសមត្ថកិច្ចបានជូនដំណឹងដល់គាត់អំពីការចោទប្រកាន់ថា គាត់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ[40]។ ចំពោះ យឹម ទិត្យ ការនេះគឺកើតឡើងនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ គឺនៅពេលដែល ស.ច.ស បម្រុង Laurent Kasper-Ansermet បានជូនដំណឹងដល់គាត់ថា គាត់ជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរដែលកំពុងធ្វើ[41]។ ដូច្នេះ ពេលវេលាពាក់ព័ន្ធគឺតិចជាង ១០ឆ្នាំ មិនមែន១៥ឆ្នាំទេ[42]។

---

[39] ចម្លើយតប កថាខណ្ឌ ៣៩ (បញ្ជាក់សេចក្ដីបន្ថែម)។

[40] *សូមមើល* សំណុំរឿង ០០៣-ឯកសារ **D120/3/1/8** សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ មតិយោបល់របស់ចៅក្រម Beauvallet និងចៅក្រម Baik ("ចៅក្រមដែលបានចុះហត្ថលេខា") ទាក់ទងនឹងអង្គសេចក្ដីនៃបណ្ដឹងឧទ្ធរណ៍ ("ញត្តិរបស់ចៅក្រមអន្តរជាតិសុំលុបចោលសេចក្ដីពិចារណា") កថាខណ្ឌ ៣៥ ជើងទំព័រ ១៣៤ *ដកស្រង់* រឿងក្ដី *Eckle* ទល់នឹង *ប្រទេសអាល្លឺម៉ង់* លេខ *8130178,* សាលក្រម ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨២ កថាខណ្ឌ ៧៣។ រឿងក្ដី *Hozee* ទល់នឹង*ប្រទេសហូឡង់* លេខ *21961/93,* សាលក្រម ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៨ កថាខណ្ឌ ៤៣។ រឿងក្ដី *Coëme និងអ្នកផ្សេងទៀត* ទល់នឹង *ប្រទេសបែលស៊ិក* លេខ *32492/96, 32547/96, 32548/96, 33209/96, 33210/96,* សាលក្រម ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ ("សាលក្រមរឿងក្ដី *Coëme ទល់នឹង ប្រទេសបែលស៊ិក*") កថាខណ្ឌ ១៣៣។

[41] ឯកសារ **D109** សេចក្ដីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២។

[42] តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECtHR") បានផ្ដល់ការយកចិត្តទុកដាក់ខ្លាំងទៅលើពេលវេលាដែលជនម្នាក់បាន*ដឹង*ជាផ្លូវការអំពីកិច្ចដំណើរការនីតិវិធី ផ្ទុយពីដោយគ្រាន់តែអត្ថិភាពនៃកិច្ចស៊ើបសួរ។ *សូមមើល ឧទាហរណ៍* រឿងក្ដី *Ustyantsev ទល់នឹង ប្រទេសអ៊ុយក្រែន* លេខ *3299/05,* ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៩១។ រឿងក្ដី *Kechev ទល់នឹង ប្រទេសប៊ុលហ្គារី* លេខ *13364/05,* ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ ៤៧។

14. សំណុំរឿងទាំងឡាយត្រូវតែសម្រេចក្នុងពេលវេលាមួយ*សមស្រប* ដោយគ្មានការពន្យារពេល *មិនសមហេតុផល*[43]។ ការវាយតម្លៃលើអ្វីដែលយើងហៅថា "មិនសមហេតុផល" ត្រូវតែធ្វើឡើង "ស្របតាមកាលៈទេសៈ" នៃរឿងក្តី នៅក្នុងនោះរួមមាន ភាពស្មុគស្មាញផ្លូវច្បាប់ ឬអង្គហេតុ នៃកិច្ចដំណើរការនីតិវិធី[44] (ក្នុងចំណោមរឿងផ្សេងទៀត ចំនួនបទល្មើសដែលបានចោទប្រកាន់

---

[43] *សូមមើលឧទាហរណ៍* វិធាន ២១(៤) នៃវិធានផ្ទៃក្នុង ("ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប"), ច្បាប់ អ.វ.ត.ក មាត្រា ៣៥ ថ្មី ដែលចែងដោយមិនត្រឹមត្រូវ "to be tried without delay" ជាសំណៅជាភាសាអង់គ្លេស ប៉ុន្តែត្រឹមត្រូវនៅក្នុងសំណៅជាភាសាបារាំង "À être jugée sans retard *excessif*" (គូសបញ្ជាក់បន្ថែម), កាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ 999 UNTS 171 មាត្រា ១៤(៣)(គ) ("ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ [...] ត្រូវ(គ) ត្រូវបានជំនុំជម្រះ *ដោយឥតពន្យារពេលយូរហួសហេតុ*" (គូសបញ្ជាក់បន្ថែម))។ អនុសញ្ញា (អឺរ៉ុប) ស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ទីក្រុងរ៉ូម ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៥០ លេខ 213 UNTS 221 (ដូចដែលត្រូវបានធ្វើវិសោធនកម្ម) មាត្រា ៦(១) ("មានសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ និងត្រឹមត្រូវនៅក្នុងរយៈពេលមួយសមស្រប", ធម្មនុញ្ញអាហ្វ្រិក (Banjul) ស្តីពីសិទ្ធិមនុស្ស និងប្រជាជន ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ លេខ CAB/LEG/67/3 rev. 5, 21 I.L.M. 58 (1982), មាត្រា ៧(១)(ឃ) ("សិទ្ធិទទួលបានការជំនុំជម្រះនៅក្នុងរយៈពេលមួយសមស្រប"), អនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស "កិច្ចព្រមព្រៀង San José, Costa Rica"San José ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ 1144 UNTS 143 មាត្រា ៨(១) ("សិទ្ធិទទួលបានការជំនុំជម្រះ [...] នៅក្នុងរយៈពេលមួយសមស្រប"), លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ៦៧(១)(គ) ("ត្រូវបានជំនុំជម្រះដោយឥតពន្យារពេលដោយមិនសមស្រប"), រឿងក្តី *Frydlender តទល់នឹងប្រទេសបារាំង សំណុំរឿងលេខ* ៣០៩៧៩/៩៦ សាលក្រម ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ ("រឿងក្តី *Frydlender*") កថាខណ្ឌ ៤៥ ("សិទ្ធិទទួលបានការធ្វើសេចក្តីសម្រេចចុងក្រោយនៅក្នុងរយៈពេលមួយសមស្រប")។ សូមមើលផងដែរ រឿងក្តី *Halilović* សំណុំរឿងលេខ IT-01-48-A សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងឧទ្ធរណ៍ភ្លាមៗ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៦ ("សេចក្តីសម្រេចលើសវនាការលើបណ្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តី *Halilović*") កថាខណ្ឌ ១៧ "សិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលដោយមិនសមស្រប មិនការពារប្រឆាំងការពន្យារពេល *ណាមួយ*នៅក្នុងកិច្ចដំណើរការនីតិវិធីទេ ប៉ុន្តែ ការពារមិនឱ្យមានការពន្យារពេល*ដោយមិនសមស្រប*" (គូសបញ្ជាក់បន្ថែម))។ រឿងក្តី *Nyiramasuhuko និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-98-42-A, សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ("សាលដីកាក្នុងរឿងក្តី *Nyiramasuhuko*") កថាខណ្ឌ ៣៦៤។

[44] *សូមមើលឧទាហរណ៍* ចក្តីសម្រេចលើសវនាការលើបណ្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តី *Halilović* កថាខណ្ឌ ១៧។ សាលដីកាក្នុងរឿងក្តី *Nyiramasuhuko* កថាខណ្ឌ ៣៦០, ៣៦២។ រឿងក្តី *Renzaho* សំណុំរឿងលេខ ICTR-97-31-A សាលដីកា អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ២៣៨។ រឿងក្តី *Šešelj* សំណុំរឿងលេខ IT-03-67-T សេចក្តីសម្រេចលើបណ្តឹងផ្ទាល់មាត់របស់ជនជាប់ចោទពីការបំពានកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០ ("សេចក្តីសម្រេចលើការបំពានកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Šešelj*") កថាខណ្ឌ ៣០។ រឿងក្តី *Ayyash និងអ្នក*

ទម្រង់នៃការទទួលខុសត្រូវខុសៗគ្នា វិសាលភាពភូមិសាស្ត្រ និងពេលវេលានៃរឿងក្តី និងបរិមាណនៃភស្តុតាងដែលមាននៅក្នុងសំណុំរឿង[45])។ ការវាយតម្លៃនេះត្រូវតែថ្លឹងថ្លែងទៅលើការខូចខាតណាមួយដែលបានចោទប្រកាន់ ធៀបទៅនឹង "ភាពចាំបាច់ជារួមដើម្បីឱ្យការស៊ើបអង្កេត និងដំណើរការតុលាការបន្តទៅមុខ"[46]។ ទាក់ទងចំណុចនេះ មានសេចក្តីពិចារណាសំខាន់ៗចំនួនបួននៅក្នុងសំណុំរឿង ០០៤ គឺ (i) យឹម ទិត្យ មិនដែលត្រូវបានឃុំឃាំងទេ ហើយក៏មិនមានការដាក់

---

*ផ្សេងទៀត* សំណុំរឿងលេខ STL-11-01/T/TC សាលក្រម អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៩៦៦។

[45] *សូមមើលឧទាហរណ៍* ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ") កថាខណ្ឌ ១៥១, ៩៩២-១០៤០ ទំព័រ ៩៧៥-៩៨៧ ដែលរៀបរាប់លម្អិតនូវឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែលបានកើតឡើងនៅទីតាំងចំនួនជាង ២០ កន្លែងនៅភូមិភាគនិរតី និងពាយ័ព្យ មុខតំណែងផ្សេងៗរបស់ យឹម ទិត្យ ក្នុងជួរថ្នាក់ដឹកនាំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទម្រង់ជាច្រើននៃការទទួលខុសត្រូវ រួមមាន សមាជិកនៃសហឧក្រិដ្ឋកម្មរួមបីផ្សេងគ្នា)។ ឯកសារ **D384** ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ កថាខណ្ឌ ២ (កត់សម្គាល់ថា មនុស្សចំនួន ២០១៤ នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤)។ ស.ព.អ កត់សម្គាល់បន្ថែមទៀតថា មុនពេលបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤ យឹម ទិត្យ គឺជាជនត្រូវចោទម្នាក់ក្នុងចំណោមជនត្រូវចោទបីនាក់។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម បានប្តឹងទៅ ស.ច.ស ក្នុងចំណោមរឿងផ្សេងទៀត អំពីការបោសសំអាត ដែលផ្តោតលើខ្មាំងផ្ទៃក្នុងនៅក្នុងភូមិភាគកណ្តាល និងភូមិភាគពាយ័ព្យ ការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍ចាម (ក្នុងភូមិភាគកណ្តាល) និងខ្មែរក្រោម (ក្នុងភូមិភាគពាយ័ព្យ) និងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងទីតាំងជាច្រើន។ *សូមមើលផងដែរ* ឯកសារ **D378/2.3** ឧបសម្ព័ន្ធ ខ – ប្រវត្តិនីតិវិធី ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ១-៣ (កម្មវត្ថុ៖ វិសាលភាពនៃបណ្តឹង) កថាខណ្ឌ ១២ (កម្មវត្ថុ៖ ការបំបែកសំណុំរឿង) កថាខណ្ឌ ១៦ (កម្មវត្ថុ៖ បរិមាណនៃភស្តុតាង)។ *សូមមើលផងដែរ* ឯកសារ **D361** សំណើរបស់ យឹម ទិត្យ សុំពេលវេលារៀបចំគ្រប់គ្រាន់ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ១៦-២៩។

[46] *សូមមើលឧទាហរណ៍* សំណុំរឿង ០០២-ឯកសារ **D314/1/8** សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និង នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៧០។ សំណុំរឿង ០០៣-ឯកសារ **D120/3/1/8** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងដីកាសម្រេចចេញសាឡើងវិញលើញត្តិរបស់ មាស មុត សុំលុបចោលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ ៣៦។ *សូមមើលផងដែរ Boddaert ទល់នឹង ប្រទេសបែលស៊ិក* No. 12919/87, សាលក្រម ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩២ កថាខណ្ឌ ៣៩ ("មាត្រា ៦ […] បង្គាប់ថា កិច្ចដំណើរការនីតិវិធីតុលាការត្រូវតែឆាប់រហ័ស ប៉ុន្តែវាក៏មានគោលការណ៍ទូទៅជាងនេះនៃរដ្ឋបាលតុលាការត្រឹមត្រូវផងដែរ។") បានអនុវត្តនៅក្នុង *Coëme និងគូកន ទល់នឹង ប្រទេសបែលស៊ិក* Nos 32492/96, 32547/96, 32548/96, 33209/96, 33210/96, សាលក្រម ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៥០។

កំហិតដ៏មានអត្ថន័យទៅលើសេរីភាពបុគ្គលរបស់គាត់ដែរ[47] (ii) បទចោទប្រឆាំងរូបគាត់ គឺមានភាពធ្ងន់ធ្ងរខ្លាំងបំផុត[48] (iii) អាណត្តិរបស់ អ.វ.ត.ក គឺត្រូវនាំយកមកជំនុំជម្រះនូវបុគ្គលទាំងឡាយណាដែលស្ថិតក្នុងយុត្តាធិការរបស់ខ្លួន[49] និង (iv) ជាកត្តាសំខាន់បំផុតនោះគឺ អ.ប.ជ បានសម្រេចជាឯកច្ឆន្ទថា ការពន្យារពេលដែលបណ្តាលមកពីការមិនបានគោរពដោយម៉ត់ចត់របស់ ស.ច.ស ទៅតាមក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបាន "ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរទៅលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ដែលត្រូវបង្ខំឱ្យដំណើរការបន្តទៅមុខ" ហើយរយៈពេលទាំងស្រុងនៃសំណុំរឿង ០០៤ ក៏មិនបានបង្ហាញគ្រប់គ្រាន់ថា ការជំនុំជម្រះប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ដោយអង្គជំនុំ អ.ជ.ស.ដ គឺមិនអាចធ្វើទៅបាន ឬខូចខាតដោយមិនអាចជួសជុលបាន[50]។ និយាយដោយខ្លី គឺមិនមានការពន្យារពេលដោយមិនសមហេតុផល និងមិនមានព្យសនកម្ម ដែលបង្ករឡើងដោយការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នាឡើយ[51]។ ការវាយតម្លៃប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយនៃកត្តានានា ផ្តល់ទម្ងន់ទាំងស្រុងទៅលើការគាំទ្រឱ្យមានការជម្រុញសំណុំរឿង ០០៤ ទៅជំនុំជម្រះ មិនមែនបិទបញ្ចប់ឡើយ។

---

[47] *សូមមើលឧទាហរណ៍* អត្ថាធិប្បាយទូទៅលេខ ៣២ កថាខណ្ឌ ៣៥។ រឿងក្តី *Abdoella តទល់នឹងប្រទេសហូឡង់* សំណុំរឿងលេខ ១២៧២៨/៨៧ សាលក្រម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩២ កថាខណ្ឌ ២៤ ("ការឃុំឃាំងជាកត្តាមួយដែលត្រូវយកមកពិចារណានៅក្នុងការវាយតម្លៃថាតើ លក្ខខណ្ឌតម្រូវនៃការធ្វើសេចក្តីសម្រេចទៅលើអង្គសេចក្តី នៅក្នុងរយៈពេលមួយសមស្រប ត្រូវបានបំពេញឬយ៉ាងណា")។ ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា កថាខណ្ឌ ៥២០។

[48] *សូមមើលឧទាហរណ៍* រឿងក្តី *Rwamakuba* សំណុំរឿងលេខ ICTR-98-44C-PT សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ កថាខណ្ឌ ១៩ ("ភាពសមហេតុផលនៃរយៈពេលកិច្ចដំណើរការនីតិវិធីត្រូវធ្វើការវាយតម្លៃទៅតាមករណីនីមួយៗដោយផ្អែកលើកត្តាមួយចំនួន រួមមាន៖ ភាពធ្ងន់ធ្ងរនៃបទចោទប្រឆាំងនឹងជនជាប់ចោទ")។ សេចក្តីសម្រេចលើការបំពានកិច្ចដំណើរការនីតិវិធីក្នុងរឿងក្តី *Šešelj* កថាខណ្ឌ ២៩-៣០។ ឯកសារ **D382** ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទំព័រ ៤៧៥-៤៨៧ (ដាក់បន្ទុកលើ យឹម ទិត្យ ពីបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មជាច្រើនប្រឆាំងនឹងមនុស្សជាតិ រួមមាន ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦)។

[49] ច្បាប់ អ.វ.ត.ក មាត្រា ១, ២ ថ្មី។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១។

[50] ឯកសារ **D381/45 & D382/43** សេចក្តីពិចារណា កថាខណ្ឌ ៧៣-៧៩ (ដកស្រង់ត្រង់កថាខណ្ឌ ៧៨)។ *ដកស្រង់* ឯកសារ **D382/22** បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ៥១។

[51] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៤៨, ៥០-៥១, ៧៣។

## V. មានតែ អ.ជ.ត.ក ប៉ុណ្ណោះអាចនាំមកនូវភាពប្រាកដប្រជាផ្លូវច្បាប់

15. មានតែ អ.ជ.ត.ក ប៉ុណ្ណោះទើបអាចនាំមកនូវសច្ចភាពចំពោះរឿងក្តីនេះ តាមរយៈការដោះស្រាយភាពមិនប្រាកដប្រជាផ្នែកតុលាការ ដែលកើតចេញពីសេចក្តីពិចារណារបស់ អ.ប.ជ[52]។ សេចក្តីសម្រេចណាមួយដែល ស.ច.ស នឹងធ្វើ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អ.ប.ជ ហើយអាចនៅចំពោះមុខ អ.ជ.ត.ក ផងដែរ ដែលធ្វើឲ្យមានបណ្តឹងវិវាទកាន់តែច្រើនទៀត។ ក្នុងនាមជាតុលាការចុងក្រោយ អ.ជ.ត.ក អាចទប់ស្កាត់កុំឲ្យមាន "វិវាទគ្មានទីបញ្ចប់" ដែលអាចមានទាំងនេះ[53]។

## VI. ដំណោះស្រាយដែលស្នើសុំ

16. អាស្រ័យមូលហេតុដូចបានរៀបរាប់ខាងលើ ស.ព.អ សូមស្នើឲ្យ អ.ជ.ត.ក៖

(i) ច្រានចោលចម្លើយតបរបស់ យឹម ទិត្យ និង

(ii) ផ្តល់នូវដំណោះស្រាយដូចបានស្នើសុំនៅក្នុងបណ្តឹងសាទុក្ខរបស់ ស.ព.អ[54]៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |

[52] *សូមមើល* បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ១៣។ *ផ្ទុយពី* ចម្លើយតប កថាខណ្ឌ ២៦ (ឲ្យដឹងថា ស.ច.ស គឺជាជម្រើសមិនមែនឥតប្រយោជន៍) កថាខណ្ឌ ២១ (ថ្លែងថា "សេចក្តីសម្រេច" របស់ អ.ប.ជ មិនអាចប្តឹងឧទ្ធរណ៍បានឡើយទៅ អ.ជ.ត.ក)។

[53] សំណុំរឿង ០០៣-ឯកសារ **D271/5 & D272/3** សេចក្តីសម្រេចរួមរបស់ អ.ប.ជ កថាខណ្ឌ ៧៧។

[54] បណ្តឹងសាទុក្ខរបស់ ស.ព.អ កថាខណ្ឌ ៧៤។